TK Garment Sisophon Co.,Ltd.

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

**រវាង**

**ក្រុមហ៊ុន ធី.ខេ ហ្គាមេន ស៊ីសុផុន**

**និង**

**តំណាងកម្មករ និយោជិត ស្តីអំពីការព្យួរកិច្ចសន្យាការងារ**

នៅថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ០៩ និង ៣០នាទីព្រឹក នៅក្នុងក្រុមហ៊ុន **ធី.ខេ ហ្គាមេន ស៊ីសុផុន** មានកិច្ចប្រជុំ រវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់ កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងខ្វះការបញ្ជាទិញ ដែលជាហេតុមិនអាចអោយចង្វាក់ផលិតកម្មរបស់រោចក្រទាំងមូលដំណើរការបាន ហេតុដូចនេះក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតចំនួន ១០៥៧នាក់ (ស្រី៨៦១ នាក់)តាមផ្នែកខ្លះៗរយៈពេល ០៨ ថ្ងៃ ដោយគិតពីថ្ងៃ០១ ខែឧសភា ឆ្នាំ២០២៣រហូតដល់ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ ។ នៅក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះ កម្មករនិយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួល ១៥ ដុល្លារអាមេរិកក្នុងមួយខែ នៃការព្យួរកិច្ចសន្យាការងារ សម្រាប់កម្មករនិយោជិតម្នាក់ៗ ។

អង្គប្រជុំបានចប់វេលាម៉ោង ១១គត់ នាថ្ងៃខែឆ្នាំដដែល ដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និងសហការគ្នាយ៉ាងរលូន ។

ថ្ងៃព្រហស្បតិ៍១កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៦

សិរីសោភ័ណ, ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣

លោក សេម វិត លោកស្វាត់ ចាន់សុំ អ្នកស្រី តាន់ ជិមលាង កញ្ញាវុទ្ធ ពេញចិត្ត **នាយកក្រុមហ៊ុន**

ធី.ខេ. ហ្គាមេន ស៊ីសុផុន TK GARMENT CO.,LTD KINGDOM OF CAMBODIA

**ស៊ិន សាត**

អ្នកស្រីយ៉ាត ផន កញ្ញាផាង សុធី អ្នកស្រីសាន ធីតា អ្នកស្រីជឿង ចាន់ណា លោកយើយ សារ៉ាំង អ្នកស្រីផុក កាន់ដាវ៉ូស៊ី

ST 7 MAKARA PHUM DEILO, SANGKAT TOEKTHLA, SEREI SOPHON CITY, BANTEAY MEANCHEY PROVINCE CAMBODIA Tel: (855) 70 954 224 Email: hr-tks@tkgarment.com